| កិច្ចតែងការ | |
|---|---|
| **មុខវិជ្ជា** | បុរេគណិត |
| **ប្រធានបទ** | កុមារស្គាល់បញ្ញត្តិរង្វាស់ |
| **ចំណងជើងមេរៀន** | ល្បែងសង់អគារ<br>ដកស្រង់ចេញពី "រឿង តើអ្នកពូកែអី?" |
| **កម្រិត** | ទាប-ខ្ពស់ ៣០ នាទី |
| **គោលបំណង** | -កុមារប្រៀបធៀប ខ្ពស់បំផុត ខ្លី ខ្ពស់ជាង ខ្លីជាង, ខ្ពស់ ខ្លីបំផុត<br>-កុមារអាចស្គាល់បញ្ញត្តិនៃការវាស់វែង និងអាចវាស់វែងដោយការសង់អគារ។ |
| **បំណិនសម្បទា** | ការប្រើចលនាកដៃក្នុងការសាងសង់ |
| **ចរិយាសម្បទា** | -កុមារមានការប្រុងប្រយ័ត្ន<br>-កុមារត្រូវមានការអត់ធ្មត់ |
| **គ្រូបង្រៀន** (ផលិតសម្ភារឧបទេស) | ប្រមូលឧបករណ៍ សម្ភារសាងសង់<br>(ឧទាហរណ៍៖ គម្របដប កែវជ័រ កំណាត់ឈើជាដើម) |
| **កុមារ** | ចែកកុមារ ជាក្រុមតូចៗ។ |
| **ការរៀបចំ** | -ដាក់ឧបករណ៍សាងសង់នៅទីកន្លែងដែលអ្នកចង់ឱ្យកុមារសាងសង់អគារនោះ។<br>-ដាក់កៅអីនៅក្បែរ ដើម្បីឱ្យពួកគេអាចឡើងបានប្រសិនបើអគាររបស់ពួកគេខ្ពស់ពេក ដើម្បីឱ្យពួកគេឡើងដល់កំពូលនៃអាគាររបស់ពួកគេ។<br>-បែងចែកកុមារ ជាក្រុមតូចៗ។ |

| សកម្មភាពគ្រូបង្រៀន | មាតិកា | សកម្មភាពសិស្ស |
| --- | --- | --- |
| ១.សួរក្មេងៗថាតើពួកគេចងចាំថាយ៉េកពូកែអ្វី ដែរទេ? ។<br>២. រំលឹកពួកគេ ប្រសិនបើពួកគេមិនចងចាំ។<br>៣. សរសេរពាក្យ "ខ្ពស់" នៅលើក្តារខៀន។<br>៤. សួរថា តើមានអ្នកណានៅក្នុងសៀវភៅខ្ពស់ជាងយ៉េកដែរឬទេ?<br>៥. សរសេរពាក្យ "ខ្ពស់ជាង" នៅលើក្តារខៀន។<br>៦. និយាយអំពីយ៉េកដែលខ្ពស់ជាងគេ។<br>៧. សរសេរពាក្យ "ខ្ពស់ជាងគេ" នៅលើក្តារខៀន។<br>៨. និយាយអំពីមនុស្សផ្សេងទៀតក្នុងសៀវភៅដែលទាបជាង។<br>៩. សរសេរពាក្យ "ទាប" និង "ទាបជាង" នៅលើក្តារខៀន។<br>១០. ឱ្យកុមារផ្តល់ឈ្មោះតួអង្គដែលទាបជាងគេនៅក្នុងសៀវភៅ<br>១១.សរសេរពាក្យ "ទាបជាងគេ" នៅលើក្តារខៀន។<br>១២.ពន្យល់ប្រាប់កុមារថា អ្នកចង់ឱ្យពួកគេសង់អគារដោយប្រើប្រាស់ឧបករណ៍ដែលបានផ្តល់ឱ្យទាំងនោះ។<br>១៣. ពន្យល់ពួកគេថា គោលដៅដែលចង់បាន គឺមិនមែនសង់អគារឱ្យបានឆាប់រហ័សនោះទេ ប៉ុន្តែគឺសង់អគារឱ្យបានកាន់តែខ្ពស់។<br>១៤. ពួកគេត្រូវធ្វើការងារជាក្រុម ហើយត្រូវធ្វើជាសមាជិកក្រុមដ៏ល្អ។ | ឧបករណ៍សាងសង់អាចជាឧបករណ៍ដូចគ្នាសម្រាប់ក្រុមនីមួយៗ ដើម្បីពិនិត្យមើលថាក្រុមណាអាចសង់អគារបានខ្ពស់ជាងគេ។<br>ឧបករណ៍សាងសង់ក៏អាចខុសគ្នាបានដែរ សម្រាប់បំផុសការពិភាក្សាបន្ទាប់ពីសង់រួច អំពីមូលហេតុអ្វីឧបករណ៍មួយប្រភេទដំណើរការបានល្អជាឧបករណ៍មួយប្រភេទទៀត។<br><br>សរសេរពាក្យទាំងនេះ ដូចជា៖<br>ខ្ពស់បំផុត ខ្ពស់ជាង ខ្ពស់<br>ខ្លី ខ្លីជាង ខ្លីបំផុត<br>ដើម្បីជួយបង្ហាញពួកគេទៅតាមទំហំនៃអក្សរ ដូចជា ពាក្យខាងលើហ្នឹង។ | ១. ចូរឆ្លើយសំណួរគ្រូបង្រៀន។<br>២. ចូរយកចិត្តទុកដាក់ទៅលើពាក្យដែលគ្រូបង្រៀនសរសេរលើក្តារខៀន ហើយព្យាយាមចងចាំពាក្យទាំងនោះ។<br>៣. ចូរធ្វើជាសមាជិកក្រុមដ៏ល្អនៅពេលលេងល្បែងសាងសង់អគានេះ។<br>៤. ចូរផ្តល់យោបល់ខ្លះៗដល់ក្រុមរបស់ខ្លួន។ នៅពេលដែលសង់អាគារ ចូរអ្នកដាក់បំណែកឧបករណ៍សង់អគារ<br>ថ្នមៗនោះទើបអគាមិនរលំ។<br>៥. ចូរកុំខឹងនឹងខ្លួនឯង និងមិត្តរួមក្រុមប្រសិនបើអគាររលំ។<br>៦. នៅពេលអ្នកពិនិត្យអគាររបស់ក្រុមដទៃ ចូររក្សាគម្លាត ដើម្បីបង្ការការដួលរលំជាយថាហេតុ។<br>៧. ចូរចូលរួមពិភាក្សាអំពីអគារដែលបានសង់រួច។ |

| | | |
|---|---|---|
| ១៥.ពិភាក្សា ដូចម្ដេចដែលហៅថាសមាជិកក្រុមដ៏ល្អ។<br>១៦. នៅពេលពួកគេកំពុងសង់ ចូរដើរមើល និងផ្ដល់ដំបូន្មានបែបស្ថាបនា តាមការចាំបាច់។<br>១៧. ប្រាប់ពួកគេឱ្យដឹង នៅពេលសល់ពេលតែ ២នាទី។<br>១៨. នៅពេលអស់ម៉ោង ឱ្យក្រុមនីមួយៗម្ដងមួយក្រុមដើរពិនិត្យមើលអគាររបស់ក្រុមដទៃ។<br>នៅពេលពួកគេមើល ពួកគេគួររក្សាគម្លាតពីអគារដើម្បីចៀសវាងការប៉ះរលំអគារទាំងនោះ។<br>១៩. ពិភាក្សាអំពីអគារដែលពួកគេបានសាងសង់។ ហេតុអ្វីបានជាអគារមួយខ្ពស់ជាងអគារមួយទៀត?<br>តើឧបករណ៍សាងសង់ធ្វើឱ្យកម្ពស់មានភាពខុសគ្នាដែរឬទេ?<br>។ល។ | | |